ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៩៧៦
ចុះថ្ងៃទី ២៥-១០-២០១១
សាលដីកា
លេខ ៖ ៣៤ "ក្រ.III.ស"
ចុះថ្ងៃទី ១០-០៦-២០១៣

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៩៧៦ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១១ ដែលមាន:

- ជនជាប់ចោទ

១- ឈ្មោះ [redacted] ឡៃ ភេទស្រី អាយុ ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រពាំងអង្គ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តបន្ទាយមានជ័យ មុខរបរលក់ធូង ឪពុកឈ្មោះ [redacted] (ស)ម្ដាយឈ្មោះ [redacted] (រ) ប្ដីឈ្មោះ [redacted] ក្រៅឃុំ។

២- ឈ្មោះ [redacted] ប៉ុស ភេទស្រី អាយុ ៥៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃឈើទាល ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត ទីលំនៅបច្ចុប្ប[redacted] ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (ស) ប្ដីឈ្មោះ [redacted]។

<u>ជាប់ចោទពីបទ:</u> បង្ករបួសស្នាមដោយចេតនា (ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិបន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស ទីលំនៅបច្ចុប្បន្នភូមិបន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

**ដំណើររឿងមានដូចតទៅ**

កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១០ វេលាម៉ោង ១៩ ល្ងាច នៅផ្ទះលោកមេភូមិបន្ទាយថ្មី

ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ជនជាប់ចោទឈ្មោះ [redacted] ប៉ុស ភេទស្រី បានទៅផ្ទះលោកមេភូមិបន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឈ្មោះ [redacted] ប៊ុនហេង ដើម្បីប្តឹងរាយការណ៍ជូនលោកមេភូមិរឿង ជនជាប់ចោទឈ្មោះ [redacted] ឡៃ ភេទស្រី ចេះតែជេរជៀមដាមខ្លួន ដោយមូលហេតុទំនាស់ក្នុងមុខរបររកស៊ីលក់ធ្យូងដូចគ្នា ហើយក៏មានការឈ្លោះពាក្យសំដីគ្នារវាងឈ្មោះ [redacted] ប៉ុស និងឈ្មោះ [redacted] ឡៃ រហូតឈានដល់ការវាយតប់គ្នាទៅវិញទៅមក ដោយឈ្មោះ [redacted] ឡៃ បានវាយទៅលើឈ្មោះ [redacted] ប៉ុស ត្រូវត្រចៀកខាងស្តាំចំនួន ២ ទៅ ៣ដៃ និងបោចសក់ឈ្មោះ [redacted] ប៉ុស ទាញធ្វើអោយដាច់សក់ ១ដុំ រីឯឈ្មោះ [redacted] ប៉ុស ក៏បានវាយទៅលើឈ្មោះ [redacted] ឡៃ វិញដែរ ដោយខ្វាចខ្វងឈ្មោះ [redacted] ឡៃ និងជេរបញ្ចោរគ្នាទៅវិញទៅមក នៅនឹងផ្ទះលោកមេភូមិបន្ទាយថ្មី។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦៣ យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោស:

ក- ឈ្មោះ [redacted] ឡៃ ភេទស្រី អាយុ ៤០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ខែ (ប្រាំមួយខែ) តែទោសនេះត្រូវព្យួរ តាមបញ្ញត្តិមាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

ខ- ឈ្មោះ [redacted] ប៉ុស ភេទស្រី អាយុ ៥៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ខែ (បួនខែ) តែទោសនេះត្រូវព្យួរ តាមបញ្ញត្តិមាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

ពីបទ បង្ករបួសស្នាមដោយចេតនា (ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិបន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២- ពិន័យឈ្មោះ យិន ឡៃ ភេទស្រី អាយុ ៤០ឆ្នាំ និងឈ្មោះ [redacted] ប៉ុស ភេទស្រី អាយុ ៥៦ឆ្នាំ ក្នុង ម្នាក់ៗចំនួន ១,០០០,០០០រៀល (មួយលានរៀល) បង់ចូលថវិការដ្ឋ ពីបទ ជេរប្រមាថ ប្រព្រឹត្តនៅភូមិ បន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣- បង្គាប់អោយឈ្មោះ [redacted] ឡៃ ភេទស្រី អាយុ ៤០ឆ្នាំ ជួសជុលសំណងថ្លៃព្យាបាល និងជម្ងឺចិត្ត សរុបចំនួន ៤,០០០,០០០រៀល (បួនលានរៀល) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មឿន ការទាមទារលើសពីនេះបដិសេធចោល។

៤- សាលក្រមនេះប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១ សម្រេចសេចក្តីចំពោះមុខជនជាប់ចោទ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ឡៃ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៣ យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទី ៣ នៃសេចក្តីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] ឡៃ ឆ្លើយថាៈ ខ្លួនប្ដឹងឧទ្ធរណ៍មិនសុខចិត្តលើប្រាក់សំណង ពេលកើតហេតុវាយគ្នាទៅវិញទៅមក ចំពោះគាត់ថ្លង់ គឺយូរហើយ មិនមែនបណ្ដាលមកពីខ្លួនវាយទេ។ សំណូមពរ ខ្លួនសុំសងទៅដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២លានកន្លះ ហើយខ្លួនប្រគល់ឲ្យឥលូវ។

ជនជាប់ចោទឈ្មោះ [redacted] ប៉ុស ឆ្លើយថាៈ ពេលកើតហេតុវាយគ្នា គាត់វាយខ្លួនបោចសក់វាយខ្លួនរហូតបាត់ក្រវិលទៀត។ សំណូមពរ ខ្លួនអត់ព្រមតាមសាលក្រមរបស់សាលាដំបូងទេ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មឿន ឆ្លើយថាៈ ខ្លួនព្យាបាលប្រពន្ធខ្លួនអស់ជាង ១០លានរៀល ខ្លួនមានសំបុត្រពេទ្យ ពេលកើតហេតុប្រពន្ធខ្លួនសន្លប់ ឈាមច្រើនណាស់ ហើយខ្លួននៅតែទាមទារសំណងដដែល។ ខ្លួនសុខចិត្តទទួលយកសំណងពីរលានកន្លះ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

សាលក្រមព្រហ្មទណ្ឌលេខ ៦៣ ឃ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេចមកមានលក្ខណៈត្រឹមត្រូវហើយ ដូច្នេះ គប្បីសភាព្រហ្មទណ្ឌតម្កល់សាលក្រមនេះទុកជាបានការដដែល។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថាៈ

១- បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ឡៃ ជាជនជាប់ចោទធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទឆ្លើយថា ខ្លួនពិតជាធ្លាប់មានទំនាស់ជាមួយនឹងឈ្មោះ [redacted] ប៉ុស ពីមុនមកមែន ពីរឿងដណ្ដើមម៉ូយធ្យូង។ នៅថ្ងៃកើតហេតុខ្លួនដើរទៅផ្ទះប្រធាន ក៏ស្រាប់តែឮឈ្មោះ [redacted] ប៉ុស និយាយអាក្រក់ពីគ្រួសារខ្លួន ក៏កើតមានជម្លោះជេរចង្អុលមុខគ្នាទៅវិញទៅមក ឈ្មោះ [redacted] ប៉ុស ខ្វាចខ្នងខ្លួន, ខ្លួនទាញសក់ក្បាល [redacted] ប៉ុស មួយទំហឹង។

៣- មានភស្ដុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ បង្ករបួសស្នាមដោយចេតនា និងពីបទ ជេរប្រមាថ ប្រព្រឹត្តនៅភូមិបន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១០ បទល្មើសមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់ស្ដីពីវិសោធនកម្ម មាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤- ភាគីជនជាប់ចោទសុំផ្តល់សំណងជាប្រាក់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.៥០០.០០០ (ពីរលានប្រាំសែន)រៀល ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏ព្រមទទួលយកដែរដើម្បីបញ្ចប់រឿងក្តី។ សំណងនេះ ភាគីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីបានប្រគល់ទទួលគ្រប់ចំនួនរួចហើយ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៦៣ យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី ៤ ស្តីពីសំណងថ្លៃព្យាបាល និងជម្ងឺចិត្ត គួរកែប្រែតាមការព្រមព្រៀងរបស់គូភាគីដូចខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ឡៃ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៣ យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចទី ៤ ស្តីពីប្រាក់សំណង និងជម្ងឺចិត្តត្រូវកែប្រែពី ៤.០០០.០០០(បួនលាន)រៀល ទៅជា ២.៥០០.០០០ (ពីរលានប្រាំសែន)រៀល វិញ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី 12 ខែ 6 ឆ្នាំ ២០១៤

ក្រឡាបញ្ជី